ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ ១៤៧ ស.ក.ប.យ

ភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## បរិយាកាសរណ៍កំដៅក្នុងទីកន្លែងធ្វើការ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត១១៩៨-៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩-០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៨៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## សំរេច

ប្រការ១.- និយោជក នៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុង មាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវរៀបចំយ៉ាងណា ឱ្យបរិយាការណ៍កំដៅក្នុងទីកន្លែងធ្វើការស្ថិតនៅក្នុងកំរិតដែលអាចទទួលយកបាន ។ បរិយាការណ៍កំដៅនេះត្រូវឱ្យសមស្របទៅនិងសុខភាពនៃអ្នកធ្វើការ ហើយមិនបង្កឱ្យមានការរំខានដល់ការងាររបស់គេទាំងពួង ។ បរិយាការណ៍កំដៅនេះត្រូវបានត្រួតពិនិត្យដោយ សីតុណ្ហមាត្រ "កែវស្ទង់កំដៅ" ដែលដាក់នៅទីកន្លែងធ្វើការ ។

ប្រការ២.- អគារ ឬ រោងជាង ត្រូវឱ្យមានមាឌ១០ម៉ែត្រគូបយ៉ាងតិច ក្នុងល័ក្ខខ័ណ្ឌធម្មតា សំរាប់កម្មករនិយោជិតម្នាក់ៗ ។ ទីកន្លែងធ្វើការត្រូវបង្ខាំងឱ្យដាច់ពីកំដៅខ្លាំងនៃពន្លឺព្រះអាទិត្យ ។ របៀបផលិតដែលមិនបញ្ចេញកំដៅ គួរទទួលយកជាឯកសិទ្ធិ ។ ប្រសិនបើការផលិតបញ្ចេញកំដៅខ្លាំង និយោជកត្រូវកាត់បន្ថយកំដៅនោះដោយ ៖

- រុំភ្ជិតឬបង្ខាំងបរិក្ខារការងារដែលបញ្ចេញកំដៅ (ដូចជាប្រពន្ធ័នាំចំហាយជាដើម)
- ស្រូបយកកំដៅនិងបញ្ចៀសកំដៅតាំងពីដើមប្រភព ។

ប្រការ៣.- ក្នុងករណីដែលទីកន្លែងធ្វើការមានកំដៅឡើងខ្លាំង ធ្វើឱ្យប៉ះពាល់ដល់សុខភាព ឬធ្វើឱ្យទើសទាល់ដល់ការងាររបស់កម្មករនិយោជិត និយោជកត្រូវរកគ្រប់មធ្យោបាយដើម្បីធ្វើឱ្យទីកន្លែងធ្វើការបានត្រជាក់វិញដូចជាដាក់កង្ហារ ម៉ាស៊ីនស្រូបខ្យល់ ឬម៉ាស៊ីនត្រជាក់ជាដើម ។

ប្រការ៤.- កម្មករនិយោជិតដែលធ្វើការនៅទីកន្លែង ដែលមានបរិយាកាសត្រជាក់ខ្លាំង ត្រូវមានសិទ្ធិទទួលបាននូវមធ្យោបាយទប់ទល់និងធាតុត្រជាក់ដូចជា ខោអាវក្រាស់ មួក ស្រោមដៃជាដើម ។

ប្រការ៥.- អ្នកប្រព្រឹត្តិល្មើសនិងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ៦. - ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ល.

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

"ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"

- គ្រប់មន្ទីរសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- សមាគមនិយោជក "ដើម្បីអនុវត្ត"
- សហភាពសហជីព "ដើម្បីជ្រាប"
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- កាលប្បវត្តិ និងឯកសារ